ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

## សូមជម្រាបជូន

## លោកជំទាវ ជា លាង អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល
## ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

***លោកជំទាវ ជាទីរាប់អាន!***

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **លោកជំទាវ** ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយក្តីរីករាយជាទីបំផុត **ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំម្សាញ់** សប្តស័ក ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៥-១៦ ខែមេសា ឆ្នាំ២០២៥ ខាងមុខនេះ សូមទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងកាយមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ។

នាឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពកោតសរសើរយ៉ាងក្រៃលែង ចំពោះគុណូបការៈរបស់ **លោកជំទាវ** ជាថ្នាក់ដឹកនាំស្ត្រីដ៏ឆ្នើមមួយរូប ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ប្រកបដោយគតិបណ្ឌិត ឧត្តមភាព ភាពជាអ្នកដឹកនាំ ក្នុងការដឹកនាំមហាអយ្យការអមតុលាការកំពូល ក៏ដូចជាបំពេញបេសកកម្មចូលរួមដឹកនាំវិស័យយុត្តិធម៌ ឱ្យប្រព្រឹត្តទៅដោយរលូន កសាងនីតិរដ្ឋ ពង្រឹងការអនុវត្តច្បាប់ និងការកិច្ចផ្សេងៗទៀតដែលជាប្រយោជន៍ដល់ប្រជារាស្ត្រ និងសង្គមជាតិ។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំនិងភរិយា សូមលើកដៃប្អូងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ឆ្នាំម្សាញ់ ព្រះនាមគោរាគៈទេវី សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះព្រំនូវសព្ទសាធុការពរជ័យ ជូន **លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ ជា លាង អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល** ទទួលនូវការរាប់អានអំពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០២៥
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**